# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៥

## ជប៉ុនផ្តល់ថវិកាសរុបចំនួន ១៧៣,៤១៣ ដុល្លារអាមេរិក សម្រាប់ការបំពាក់ឧបករណ៍បរិក្ខារពេទ្យ ក្នុងខេត្តពោធិ៍សាត់ និងការសាងសង់អគារវះកាត់ ក្នុងខេត្តតាកែវ

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាសរុបចំនួន ១៧៣,៤១៣ ដុល្លារអាមេរិក ដល់ស្រុកប្រតិបត្តិចំនួនពីរ។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយនិមួយៗសម្រាប់គម្រោងដូចតទៅ៖

១. គម្រោងបំពាក់ឧបករណ៍បរិក្ខារពេទ្យនៅមន្ទីរពេទ្យបង្អែកបាកាន ក្នុងខេត្តពោធិ៍សាត់ (ថវិកាចំនួន៨៣,០៨០ ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយ៖ ស្រុកប្រតិបត្តិបាកាន ខេត្តពោធិ៍សាត់

គម្រោងនេះ គឺបំពាក់នូវឧបករណ៍បរិក្ខារពេទ្យចំនួន៥រួមមាន៖ ម៉ាស៊ីនថតដោយកាំរស្មីអ៊ិច ម៉ាស៊ីនអេកូសាស្រ្ត កៅអីសម្រាប់ទន្តពេទ្យ ម៉ាស៊ីនវិភាគឈាម និងម៉ាស៊ីនវិភាគគីមី។ យើងរំពឹងថា គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ជូនដល់ប្រជាជននៅក្នុងតំបន់ប្រមាណជា ១៦០,០០០នាក់ អោយទទួលបានសេវាសុខភាពកាន់តែល្អប្រសើរជាងមុន ។

២. គម្រោងសាងសង់អគារវះកាត់នៅមន្ទីរពេទ្យបង្អែកព្រៃកប្បាស ក្នុងខេត្តតាកែវ (ថវិកាចំនួន ៩០,៣៣៣ ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយ៖ ស្រុកប្រតិបត្តិព្រៃកប្បាស ខេត្តតាកែវ

គម្រោងនេះ គឺសាងសង់អគារវះកាត់មួយខ្នង ដើម្បីសម្រួលដល់ផ្នែកវះកាត់នៅក្នុងមន្ទីរពេទ្យបង្អែកព្រៃកប្បាសអោយកាន់តែប្រសើរឡើង។ យើងរំពឹងថា គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជននៅក្នុងតំបន់ប្រមាណជា ១៦០,០០០នាក់ អោយទទួលបាននូវសេវាសុខភាពល្អប្រសើរជាងមុន។

*ជំនួយឧបត្ថម្ភឥតសំណងគូសាណូណិរបស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥៤.១លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន៥៣៨ គម្រោង នៅទូទាំងប្រទេស។


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*